# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ ផែង ប៊ីក ភេទស្រី អាយុ៧៧ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហមៈ យុទ្ធនារីកងចល័ត
## ស្រុកកំណើតៈ នៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ
## សព្វថ្ងៃរស់នៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ
## ថ្ងៃទី១៤ ខែ ឧសភា ឆ្នាំ២០១៣
## សម្ភាសន៍ដោយ ៈ ឡុង ដានី
## ២១ ទំព័រ
## ០០:៣៩:២៣

ដានីៈ បាទ! អ៊ីជីបូនខ្ញុំចង់ណែនាំជម្រាបប្រាប់អ៊ី ខ្ញុំឈ្មោះ ដានី ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញណាអ៊ី បាទហើយខ្ញុំមកជួបអ៊ីនេះគឺចង់ដឹងពីជីវិត កាលរស់នៅរបស់អ៊ីតាំងពីក្មេងរហូតមកឆ្លងកាត់សង្គ្រាមមក ពិបាកស្រណុកអីយ៉ាងម៉េចណា មកដល់បច្ចុប្បន្នណា ។

ប៊ីកៈ នៅសង្គ្រាម ពីដើមលំបាកណាស់ ។

ដានីៈ ជីបូនខ្ញុំចង់ស្គាល់ឈ្មោះ អ៊ី អ៊ីឈ្មោះអីដែរ?

ប៊ីកៈ ផែង ប៊ីក ។

ដានីៈ បាទ?

ប៊ីកៈ ផែង ប៊ីក ។

ដានីៈ អី ប៊ីក អ៊ី?

ប៊ីកៈ ផែង ប៊ីក ។

ដានីៈ ផែង ហ៎? ផែង ប៊ីក! អាយុប៉ុន្មានហើយអ៊ី?

ប៊ីកៈ ៧៧ហើយ ។

ដានីៈ អ៊ូ! ៧៧ឆ្នាំហើយណ៎?

ប៊ីកៈ ចា៎ស!

ដានីៈ អ៊ូ! បានអាយុវែងណាស់អ៊ី ។

ប៊ីកៈ ចា៎ស!

ដានីៈ ហើយ អ៊ី ស្រុកកំណើតកើតជានោឯណាទៅ?

ប៊ីកៈ កើតនៅនេះឯង ។

ដានីៈ កើតនៅភូមិ កោះកេរ្តិ៍?

បឹកៈ ចាស! ផ្ទះនៅឯង ។

ដានីៈ ផ្ទះហ្នឹងបណ្ដោយ!

បឹកៈ ដីនេះឯង ។

ដានីៈ ឃុំអីដែរនៅឯហ្នឹង?

បឹកៈ ឃុំស្រយ៉ង់ ។

ដានីៈ ឃុំស្រយ៉ង់ ។

បឹកៈ ស្រុកគូលែន ។

ដានីៈ ឃុំស្រយ៉ង់ ស្រុកគូលែន ។

បឹកៈ ពីដើមមិញ យើងទៅសៀមរាបទេ ប៉ុនសព្វថ្ងៃចូលខាងគូលែន ។

ដានីៈ ស្រុកគូលែន ខេត្តអីទេអីទៅ?

បឹកៈ ខេត្តអីទេ សព្វថ្ងៃគេហៅថាខេត្តៗ ។

ដានីៈ ខេត្តព្រះវិហារ?

បឹកៈ ខេត្តព្រះវិហារ ។

ដានីៈ បាទ! សព្វថ្ងៃ អ៊ុំរស់នៅភូមិណាដែរ?

បឹកៈ រស់នៅភូមិនេះ ។

ដានីៈ ភូមិហ្នឹងគេហៅភូមិអីដែរឥឡូវ?

បឹកៈ កោះកេរ្ដិ៍ ។

ដានីៈ កោះកេរ្ដិ៍ដែរ?

បឹកៈ ចាស!

ដានីៈ ឃុំស្រយ៉ង់ដដែលណាហ្នឹង?

បឹកៈ ឃុំស្រយ៉ង់ ។

ដានីៈ ស្រុកគូលែន ។

បឹកៈ នៅខាងខេត្តសៀមរាបហ្នឹងណា តាំងពីចប់សង្គ្រាមនៅខេត្តខាងនេះ ។

ដានីៈ អ៊ុំ លោកតាឈ្មោះអីដែរ គ្រួសារអ៊ុំ?

បឹកៈ ហ៊ូ! តានេះគាត់ស្លាប់យូរណាស់ហើយ ។

ដានីៈ គាត់ឈ្មោះអី?

បឹកៈ ឌឹម ។

ដានីៈ ឈ្មោះ ឌឹមហេ៎?

បឹកៈ ចាស!

ដានីៈ ហើយ ឪមអីដែលលស្លាប់? គាត់ត្រកូលអីគេឪម?

បឹកៈ ទុំ ឪម ។

ដានីៈ ទុំ ឪម ហេ?

បឹកៈ ចាស! ស្លាប់នៅសម័យយួនចូលហើយ គេចាប់យកទៅខេត្ត ចាប់ស្លាប់អស់ខ្ញុំក៏យកនៅបែកបាក់ ។

ដានីៈ ចាប់! ម៉េចបានយួនយកទៅខេត្ត?

បឹកៈ បើយួន មិនដឹងរឿងនរណាគេជាអ្នកបង្កើត រឿងអីនោះ ។

ដានីៈ យួនបង្កើតរឿងថាម៉េច?

បឹកៈ វាផ្ទុះមីនឯណានោះ ហើយថាគ្នាយកមីនទៅដាក់ទៅអីឯណា មនុស្សខ្លាចហ្នឹងរាប់ ទៅដាក់មីននៅឯណា ចាស់ហើយ! មនុស្ស៥០ទៅហើយ ៥៥ រូបគេចាប់ទៅដាក់ ដាក់គុកជីផងដែលរស់អី ។

ដានីៈ យកមីនទៅដាក់ឲ្យផ្ទុះយួនអី?

បឹកៈ អើ! គេចោទ គេចោទឯណា ។

ដានីៈ គាត់ស្លាប់ក្នុងគុក ឬក៏គេសម្លាប់?

បឹកៈ ស្លាប់ក្នុងគុក មិនមែនស្លាប់ទេ មិនដឹងជាស្លាប់អីទេ ចុះមិនឃើញមិនដឹងយួនវានៅ ខ្មែរក្រហមវាជម្លៀសទៅលើនោះ ឡើងភ្នំទៅនៅថៃទៅនោះ ។

ដានីៈ ចាប់យកទៅបាត់រហូតតែម្តង?

បឹកៈ ១០ឆ្នាំ បាត់រហូត ។

ដានីៈ ចុះអ៊ុំ មានកូនចៅប៉ុន្មាននាក់?

បឹកៈ កូនស្លាប់អស់ហើយ នៅបីទេសព្វថ្ងៃ នៅប្រធានភូមិនេះមួយ កូននោះណា ។

ដានីៈ កូនប្រធានភូមិ ខឿនហេ?

បឹកៈ ចាស! ក៏នៅស្រី២ប៉ុណ្ណោះឯង ។

ដានីៈ កូនបីនាក់ ។

បឹកៈ នៅបីនាក់ប៉ុណ្ណោះឯង ។

ដានីៈ ប្រុសមួយ ស្រី២ ។

បឹកៈ ស្លាប់ពីខែផល្គុន ឆ្នាំទៅនេះមួយ អាផ្ទះបៀតប្រធានភូមិនេះណា ស្លាប់ឆ្នាំទៅ ខែផល្គុន ។

ដានីៈ ហ៊ូចឹងហេ! អ៊ុំចុះឪពុកម្តាយអ៊ុំគាត់អីទៅ ដែលគាត់ថារស់នៅក្នុងភូមិហ្នឹងតាំង?

បឹក:	ផែន! ហ៊ូ ។

ដានី:	ឪពុកឈ្មោះ ផែន?

បឹក:	ឪពុកឈ្មោះ ផែន ។

ដានី:	ឪពុកឈ្មោះផែន ចុះម្តាយ?

បឹក:	ម្តាយ កែវអីទេភ្លេចអស់ហើយ យាយហ្នឹង យាយអីទេ ភ្លេចហើយ ឈ្មោះ យាយសោមអ៊ំ សោម កែវ ម៉ែ ។

ដានី:	បាទ?

បឹក:	ម៉ែខ្ញុំណា យាយគាត់ឈ្មោះ សោម ។

ដានី:	ឈ្មោះ សោម?

បឹក:	ឈ្មោះ សោម យាយ សោមៗ ។

ដានី:	ម្តាយអ៊ុំឈ្មោះ សោមហ៎?

បឹក:	ម៉ែ កែវ ម៉ែខ្ញុំឈ្មោះកែវ ។

ដានី:	ម្តាយឈ្មោះកែវ ។

បឹក:	ស្លាប់អស់ហើយ ។

ដានី:	ហើយអ៊ុំមានបងប្អូនបង្កើតប៉ុន្មាននាក់ទៅ?

បឹក:	បង្កើតៗទេ ខ្ញុំមានតែ២នាក់ ស្រីទាំងអស់គ្នាហ្នឹង នៅវិចេកមួយខ្ញុំ ខ្ញុំនៅនេះមួយ ។

ដានី:	ពីកំណើតកើតជាមក មានប៉ុន្មាន?

បឹក:	មាន២,៣,៤នាក់ហើយក៏ស្លាប់យូរណាស់ហើយ អាមួយនោះស្លាប់ដែលគេកំពុងធ្វើស្តីនោះណា

ដានី:	ធ្វើអីគេ?

បឹក:	អាមុនដំបូងដែលគេ ហៅទៅចឹងទៅណា អាស៊ិន អាអីនោះ គេធ្វើការខាងស្អីទេ ស្លាប់មួយ ។ បើ អាប្អូននោះស្លាប់ឈឺទេ បើអាធ្វើទាហាននេះស្លាប់គេបាញ់ចោលដឹង បានផាប់ហ្នឹងក្បាលខ្លានេះឯង ។

ដានី:	បាទៗ! ចុះអ៊ុំ កាលពីក្មេងៗមក អ៊ុំរស់នៅហ្នឹងតែម្តង?

បឹក:	ចាស៎!

ដានី:	ចុះកាលពីក្មេងមកអ៊ុំបានរៀនសូត្រទេ? ចេះអក្សរទេ?

បឹក:	ពុំបានចេះទេ ពុំបានរៀនទេ សម័យនោះ ។

ដានី:	អត់ចេះអក្សរទេអ៊ុំ?

បឹក:	អត់ចេះទេ ។

ដានី: អានអីអត់ដាច់?

បឹក: អ្នកចេះបានទៅប្ញទៅរៀនអីទេ បានចេះនោះ សម័យនោះ អត់សាលារៀនទេ។ បើសម័យ នេះបានមានសាលារៀន។ សម័យប៉ុល ពត ក៏គេមានសាលារៀនណា ពីដើមមិនដែលមានសាលាទេ ចឹងបានចាស់!ល្ងង់ណា ព្រោះអត់សាលា។

ដានី: កាលពីដើមមកស្រុកយើងអ៊ូរអរទេ កាលពីជំនាន់មុនសង្គ្រាមណា?

បឹក: ចុះមានទៅស្អី។

ដានី: មនុស្សច្រើនទេ?

បឹក: ច្រើន! តាមនេះសុទ្ធតែមនុស្ស ផ្ទះរៀងទៅនោះផ្ទះធំ សព្វថ្ងៃដែលមកពីសង្គ្រាមចប់ហើយ គេទៅនៅរំបេកអស់ពាក់កណ្ដាល ទៅនៅឯនោះពាក់កណ្ដាល កន្លងភូមិគេធំណា។

ដានី: ចុះកាលពីដើមមក មានវត្តមានអីទេ?

បឹក: មានវត្ត វត្តនៅខាងត្បូងភូមិយើងនេះ ផ្ទះយើង។

ដានី: ជិតនេះដែរចឹង?

បឹក: អើ! វត្តអាបៀតបន្ទាយនេះឯង សព្វថ្ងៃគេអត់ឲ្យធ្វើវត្ត។

អ្នកជិតខាង: ពីណាមិនឲ្យធ្វើ(សើច)?

បឹក: ចុះមែនបៀតទៅទីនោះឯណា អាវត្តមកនេះបន្តិចទៅណា ល្មមហ្នឹងវត្ត។

អ្នកជិតខាង: គេឲ្យធ្វើឥឡូវ?

ដានី: អប្សរាអត់ឲ្យធ្វើ។ មានទៅគៀក បៀតកំផែងណា ប្រាសាទឯណា។

អ្នកជិតខាង: ផ្លូវនេះគេមិនឲ្យធ្វើផង ផ្លូវនេះ។

បឹក: ផ្លូវនេះគេពុំឲ្យធ្វើ ធ្វើតែត្រឹមនេះទៅនេះ ឯណោះគេអត់ឲ្យធ្វើ ប៉ះពាល់គេ។

ដានី: ហ៊ូ!ចឹងកាលពីដើម ពីសង្គមមកមានវត្តមួយនៅជិត?

បឹក: មានវត្ត។

ដានី: មានវត្តនៅជិតប្រាសាទហេ៎?

បឹក: ចា៎ស! វត្តបៀតប្រាសាទនេះឯង។

ដានី: ជាប់របងប្រាសាទតែម្ដង?

បឹក: នោះហើយ?

ដានី: ចុះវត្តហ្នឹង បាត់ទៅណាទៅ?

បឹក: វត្តបាត់ទៅណាកាលពីសង្គ្រាមនោះ ក៏បាត់លោកទៅព្រោងព្រាតអស់។

ដានី: ចុះវត្តគេយកធ្វើអីវិញទៅ?

បឹក: គេធ្វើអី យកសសរ យកអីទៅណាអស់ធ្វើអី ។

ដានី: ជំនាន់ណាដែលគេយកធ្វើហ្នឹង?

បឹក: ហ៊ឹមយូរហើយ! មិនដឹងជាជំនាន់ណាទេ ។

ដានី: ជំនាន់ប៉ាយរួម?

បឹក: ទេ! មុននោះទៀត ។

ដានី: មុនប៉ាយរួមទៀត?

បឹក: ហ្នឹងឯង ។

ដានី: គេរុះវត្តតែម្តង ឬយ៉ាងម៉េច?

បឹក: គេរុះចោល!

ដានី: ខ្មែរក្រហមអ្នកប៉ុល ពត គេអ្នករុះ ឬក៏យ៉ាងម៉េច?

បឹក: មិនមែនថាគេរុះគេដុះគេអីដែលណា មើលតែផ្ទះយើងបែកទៅមាននរណាគេនៅ គេដុតចោលៗអស់ អើ!

ដានី: ហើយប្រជាជនយើងសង់វត្តដែរ ប៉ុន្តែអបរ្សាយើងអត់ឲ្យសង់?

បឹក: ចង់តា! ចងធ្វើវត្តតែអបរ្សាគេអត់ឲ្យសង់ អបរ្សាគេមិនឲ្យ ។

ដានី: ឆ្នាំណាដែលអបរ្សាគេពុំឲ្យធ្វើ?

បឹក: ចុះគេពុំឲ្យធ្វើប៉ុណ្ណោះ មើលតែដីគេដើររកដោះយកអស់ហើយ ដីទីនេះគេពុំចង់ឲ្យនៅផង តែខ្ញុំដេចេសនៅរហូតសព្វថ្ងៃ មិនដឹងទៅរកដីឯណាទៀត មានតែដីទីនេះឯង បើថាគេមិនឲ្យនៅក៏មានតែសុំលុយ សុំកាក់គេ រកកទិញដីទិញអីធ្វើ មានតែប៉ុណ្ណឹងឯង ។

ដានី: ចុះអ៊ុំចឹង! កាលពីក្មេងអត់ដែលរៀនសូត្រទេ?

បឹក: អត់ទេ!

ដានី: អាយុប៉ុន្មាន អ៊ុំរៀបការ?

បឹក: អាយុ១៩,១៩ឆ្នាំ ។

ដានី: រៀបការណ៍តាំងពី១៩ឆ្នាំណ៎?

បឹក: ចា៎ស!

ដានី: ចុះលោកតា គាត់អ្នកនៅភូមិណាដែរ?

បឹក: នៅនេះឯង ភូមិនេះ ។

ដានី: នៅភូមិនេះដែរ?

បឹក: នៅភូមិនេះ ទាំងអស់គ្នា ។

ដានី: ដល់ពេលលោកយាយអ៊ុំ ការហើយធ្វើអីដែរ?

ប៊ីក: មានធ្វើអី ធ្វើតែស្រែចម្ការនេះឯង ភូមិយើងមកនេះមានធ្វើអី។

ដានី: កាលហ្នឹងធ្វើស្រែ ធ្វើចម្ការនៅឯណាទៅដីស្រែ ដីចម្ការ?

ប៊ីក: ដីស្រែនោះបៀតសាលារៀន។

ដានី: មានសាលារៀននោះហ៎?

ប៊ីក: ចា៎ស!

ដានី: កាលហ្នឹងមមានដីប៉ុន្មានទៅ?

ប៊ីក: កើតទេ មានតែប៉ុណ្ណោះឯង កាលនោះឲ្យទៅកូននៅឯនោះមួយ។

ដានី: មានប៉ុន្មានហិចតា?

ប៊ីក: ហ៊ឺម! ១ហាត់ទេ បើឲ្យទៅកូនអាប្រុសដែលស្លាប់នោះប្រហែល២ហាត់ នឹងហើយ កាត់ដីឲ្យកូនប៉ុណ្ណោះឯង។ កាត់បញ្ចូលវិញ ចូលគ្នាអស់ហើយ។

ដានី: ចុះហ៎ ចឹងអ៊ុំកាលពីមុនធ្វើស្រែ ធ្វើចម្ការ ចុះស្រុកភូមិយើងកាលនោះ ស្រលះចឹង ឬក៏សុទ្ធតែព្រៃ សុទ្ធតែអី?

ប៊ីក: ព្រៃ កាលហ្នឹងមានស្រលះណា។

ដានី: ចុះប្រាសាទអីកាលជិនាន់ហ្នឹងយ៉ាងម៉េចដែរ មានភ្ញៀវអីគេមក?

ប៊ីក: ភ្ញៀវអីដូចតែគ្នាហ្នឹងណា គ្រាន់ទេគេពុំបានត្រួស ពុំបានឆ្ការ ពីសង្គម។

ដានី: ពីសង្គមវាយ៉ាងម៉េចដែរនៅក្នុងប្រាសាទហ្នឹង?

ប៊ីក: ស្កុកជិតណា។

ដានី: ស្កុកជិត ព្រៃជិតនេះណា

អ្នកជិតខាង: ប៉ុនឥឡូវគេធ្វើស្អាត។

ប៊ីក: ស្អាតបាក់អស់ហើយ ជ្រះចេញកាលណាវាភ្លៀង វាចេះចូលចុះៗមក វាបាក់កំពូលមក យើងពីដើមមានស្អី អត់រស់ អត់ឆ្ការចុះ វាបានដើមឈើជួយវាចាក់ឬសនេះទៅមានស្អីវាមិនបាក់។ នេះសព្វថ្ងៃមានឃើញទេ អត់ឲ្យឡើងបាក់ មកបាក់គំនរអស់។

ដានី: ដល់ពេលយើងត្រួសព្រៃត្រួសអីស្អាតទៅសព្វថ្ងៃទៅបាក់វិញ?

ប៊ីក: បាក់ដីរលុង។ បើដីវាច្រោះតាមថ្ម បើដីវាច្រោះតាមថ្មមកអស់ហើយ ទៅណាបើវាមិនបាក់។ យើងពីដើមមួយអាយុតាំងពីយាយតាម៉ែឪយើងមិនដែរទៅត្រួសឆ្ការ។ ត្រួសក៏ត្រួសចេះឯង ប៉ុនត្រួសៗកាប់តែអាតូចៗចេះឯង អាធំគេអត់កាប់ទេ។ នេះកាប់ចេញទាំងអស់ហើយ ស្រលះចេញមិនឃើញទេ បាក់។

ដានី: ចុះអ៊ុំមាននិយាយប្រាប់ចឹងទៅអប្សរាទេ?

បឹក: ហ៊ើ! មិនដឹងនិយាយធ្វើអីទេ ។ គេធ្វើស្អាតហើយទៅនិយាយចុះ គេខឹងទៀត ។

ដានី: បាទ! ចឹងកាលពីដើមមកសតបាទ!ចឹងកាលពីដើមមកសត្វព្រៃ សត្វអីច្រើនហ៊ើ?

បឹក: ហ៊ូ! ដំរីក៏មាន ទន្សោងក៏មាន មានតែកាត់មកនេះឯងស្រុកណា ពីដើមនោះ ទាំងភូមិៗ វាកាត់ដើរទៅតាមស្រែទៅកើតនៅទីនោះឯង ។ ដំរីក៏នេះ ស្រែតាមនេះ បើពិបាកទៅដេកចាំ វាហ្នឹង វាមកបោកស្រូវស៊ី ។

ដានី: ដំរី?

បឹក: ដំរី! នេះអានេះអាស្រែខាងកើតនេះ សព្វថ្ងៃមើលៗ តាំងពីសង្គ្រាមមិនដឹងជាទៅខាងណាអស់ មិនឃើញគន្ធងមកមួយ ទន្សោងស្អីៗ មិនឃើញទេសព្វថ្ងៃ ។ មិនដែលស្គាល់ទេ ទន្សោងនេះ កូនចៅក្រោយពុំស្គាល់ទន្សោង ប្រើសទេ នៅតែឈ្លូស ជ្រូក ប៉ុណ្ណោះឯងសព្វថ្ងៃ គេបានអន្ទាក់ ដាក់អី ក៏បានស៊ីមួយមួយទៅ ហិនអស់ហើយគ្មានឃើញអីទេ វារត់ទៅរកព្រៃធំអស់ហើយ ។ ពីដើមដើររត់ដើរជញ្ជាត់ រត់តែដំរីឡើងឈររន្ទាត់រន្ទាយ ឃើញដំរី នាំគ្នារត់ឡើងដើមឈើ ឡើងរញ៉ៅឈររទេវាទៅខ្ទនវា វាក្រោកពីដេកទឹកត្រជាក់រូតៗទៅ ។

ដានី: ចុះអ៊ុំដល់ពេលឆ្នាំណាទៅបានមានសង្គ្រាមនៅស្រុកភូមិយើង?

បឹក: មិនដឹងជាឆ្នាំណាទេ មិនសូវស្គាល់ហ្នឹងគេ មិនដឹងជាចិតស្អីប៉ុន្មានទេ ។

ដានី: គេរដ្ឋប្រហារនៅ ទម្លាក់សម្ដេច?

បឹក: រដ្ឋប្រហារមិនស៊ីបាយរួម ។

ដានី: ចុះអ៊ុំ នៅស្រុកយើងស៊ីបាយរួមយ៉ាងម៉េចខ្លះទៅ?

បឹក: ហ៊ូ! ស៊ីបាយរួមមិនចេះនិយាយទេ ។

អ្នកជិតខាង: អត់វាយចោលទេយាយខាងនេះ?

បឹក: វាយតា! ប៉ុនគេអាអ្នកស្រុកភូមិឯងពុំដែលវាយទេ មានតែអ្នកចំណាយទេដែលមក ។

អ្នកជិតខាង: ខាងនោះទូទៅហើយ វាយទាំងអស់នោះ ។

បឹក: អត់ទេ!

ដានី: ពេលនោះគេវាយចោលអ្នក១៧មេសាហ៊ើ?

បឹក: អើ! គេវាយចោលតែអ្នកឆ្ងាយៗទេ អ្នកដែលមកពីណា ដូចថាគ្នាចង់រស់ៗណា វាមិនបាន រស់ទៅកើតក៏ចាប់បាន យកចិញ្ច្រាំនោះហើយ ជំនាន់បាយរួមនោះ ប៉ះបាយវាល់ៗ ចាន ប៉ុណ្ណេះៗ មួយចានៗ បើដាច់ខ្វាំងក៏អន្ទក់នៅតិចតួចក៏ដើមចេក យកមកហាន់ៗក៏ដាក់ដិ ចែកគ្នាមួយចានៗហូបទៅជំនាន់នោះណា ធ្វើស្រែរួម ហូបបាយរួម រកតែអំបិលបង់អន្ទរ

ដាច់ដួនណា ទៅណានោះដាច់ មិនកើតអីរឿងតាក់តិច ខ្លះក៏ទៅរកផ្សិតខ្លះក៏ស្ទីទៅក៏យកមកដាក់ស្ងោហុតទាំងអស់គ្នារស់ កាល(ស្តាប់ពុំបាន) កម្មណាស់កូនមិចង់និយាយទេកំសត់ណាស់ មួយសារនោះ សម័យនោះ ។ បើយើងខ្មែរក្រហមយកទៅ អានោះដូចជាកម្មៗ វាស៊ីស្រួលណា អង្ករសំរូប មែន តែអង្ករទាំងបេៗនោះ រត់នឹងយួនវាយបើមិនចាក់ចោលទំពាសស្តាយមួយរត់ដាន់គ្នាទាំង យប់នោះឯង ហ៊ូ! កម្មបានឆ្លងផុតហើយ បានរស់រានវិញ ។

ដានី: ចុះកាលជិនាន់បាយរួម លំបាកហ៉េ?

បឹក: លំបាកណាស់ ។

ដានី: ជំនាន់បាយរួមគេឲ្យធ្វើអីខ្លះ?

បឹក: មានធ្វើការងារអី ធ្វើតែស្រែ ឲ្យទៅបោចស្នោ ។

ដានី: គេឲ្យបោចស្នោទៀត?

បឹក: បោចស្នោហើយនឹង សន្ទូងណា ។ ស្ទូងបានហើយ ចុះបើយើងសព្វថ្ងៃធ្វើបានហើយស្រូវគេលក់ឡើងគគ្រឹក បានទៅ(ស្តាប់ពុំបាន) ។

ដានី: កាលហ្នឹងគេឲ្យយើងធ្វើស្រែ បោចស្នោ ហើយបាយរួម?

បឹក: បាយរួម ។

ដានី: កាលហ្នឹង នៅហូបបាយ ហូបបាយសុទ្ធ?

បឹក: ហូបបាយប៉ុននៅរួមនោះឯង ។

ដានី: អត់មានហូបបបរទេ?

បឹក: ទេ! បើវានៅតិចបានបបរ ។ បើស្រូវអង្ករនៅមួយពីរជន្រុក បាយ! បានដាំវាលាយចែកគ្នា ។

ដានី: គេឲ្យនៅផ្ទះរាងខ្លួន ឬនៅរួម?

បឹក: នៅផ្ទះរាងៗខ្លួន ប៉ុនព្រឹកៗឡើងក៏ទៅរោង ។ អ្នកណាក៏គេត្រូវសេដ្ឋកិច្ចដាំបាយទៅក៏ទៅណាដាំស្ល ។

ដានី: រោងបាយនៅឯណា?

បឹក: នៅឯភូមិ ត្រង់ផ្ទះកូនខ្ញុំប្រធានភូមិនេះឯង នៅភូមិមួយណា ។

ដានី: អាហ្នឹងរោងបាយគេ?

បឹក: រោងបាយគេ ។ នៅនោះអាចុងភូមិមរោងបាយមួយ ។

ដានី: រោងបាយ បាយពីចឹង?

បឹក: រោងបាយពីរ ។

ដានី: ចឹងមួយថ្ងៃហូបប៉ុន្មានពេល?

បឹកៈ ហ៊ូ តែព្រឹកល្ងាចទេណា ។

ដានីៈ តែព្រឹកល្ងាចទេ?

បឹកៈ តែព្រឹកល្ងាចទេ ។

ដានីៈ អត់បីពេលដូចយើងឥឡូវទេ?

បឹកៈ អត់ទេ! បើយើងសព្វថ្ងៃ ។

ដានីៈ ចុះប្រធានៗគេមកពីណាមក?

បឹកៈ ប្រធានៗ នៅភូមិហ្នឹង ងាប់អស់ហើយអាអ្នកប្រធានហ្នឹង ។

ដានីៈ ពីណាគេឈ្មោះអី?

បឹកៈ ឈ្មោះ អាសាមិត្ត, អាសឹត,អានី បីនាក់ ស្លាប់អស់ហើយនៅតែតាម៉ឹងទេសព្វថ្ងៃ អានោះក្រ ទេ មេគេអោបក្តាប់ខាងទឹកបាយហ្នឹងណា ផុតពីនោះផង អាសឹតនោះចង្កេនៅហ្នឹង ចង្កេ នៅភ្លឺស្រែនេះណាក្បែរផ្ទះ ។ បើអាម្នាក់នោះបែបស្អីទេចូលមក មកមួយសារនេះ ដឹងគេដូចទី ណាទេគេមករកចាប់មករកអីក៏រត់ រត់ទៅក៏ទៅចង្កេនៅឯស៊ឹងហ្នឹងណា ។

ដានីៈ ពីណាគេអ្នកចង្កេហ្នឹង?

បឹកៈ អាប្រធាននោះ ។

ដានីៈ ប្រធានឈ្មោះអី?

បឹកៈ អានោះ អាសាមិត្ត ។

ដានីៈ ឈ្មោះ សាមិត្តហ៎?

បឹកៈ ចា៎ស!

ដានីៈ សាមិត្ត គាត់ចង្កេ?

បឹកៈ ចង្កេ ចង្កេ ក៏មិនមាននរណាឃើញ ក៏ជ្រុះជ្រកទៅខ្លួនវា ឃើញតែកន្សែងទេ គេទៅអូសថ្នង ធ្វើផ្លូសក៏អូសទៅក៏បេះក៏គាត់ងើយទៅបេះក៏ឃើញវាបក់រំភើយៗ ក៏ស្តីអាណាចង្កេដឹងកន្សែង គាត់ថា ក៏ស្រាប់តែមកមើលគាល់នោះឃើញសាមិត្ត ស្គាល់សាមិត្តវាទេ បានថាអានោះ ចង្កេ ។ ហើយវាបាត់យូរណាស់ហើយណា មិនដែលកើតបាយកើតទឹកអីស៊ី វាចិត្តដាច់ក៏ឡើងចង្កេ នៅឯនោះឯងដើមជ្រៃ ។

ដានីៈ ម៉េចបានជាគាត់ចង្កេ គាត់ភ័យ?

បឹកៈ ភ័យគេរកចាប់ ។

ដានីៈ ភ័យគេរកចាប់ នរណាគេរកចាប់?

បឹកៈ ចង្កេ នោះភ័យគេរកចាប់នេះដូចគ្នា ។

ដានី៖ ពីណាគេរកចាប់គាត់ គាត់ធ្វើប្រធានអី?

បឹក៖ ទេ! គាត់ដឹបូងមិនដឹងជាស្អី យោធាអីគេ កំពុងនៅយោធាណាណា ខ្មែរយើងគេចាប់ ។

ដានី៖ ចុះកូន ចុះអ៊ុំកូនចៅអីនៅជុំគ្នាអត់នៅសម័យបាយរួម?

បឹក៖ នៅជុំគ្នាណាជុំទាំងអស់ មិនទាន់មាននរណាមានប្តីប្រពន្ធមួយទេ ។

ដានី៖ អត់ទាន់មាន?

បឹក៖ ហ៎ា! ដូចជាបានមួយ បានអានេះ ឈប់ពីរួមហើយទេបានអានេះគេបានប្រពន្ធសព្វថ្ងៃហ្នឹង ។

ដានី៖ បាទ! ប៉ុន្តែកាលជំនាន់ហ្នឹងគេអ៎ ប៉ុលពតគេឲ្យយើងនៅផ្ទះ កូនចៅអីគេនៅផ្ទះជុំគ្នា ឬក៏បំបែកឲ្យនៅតាមកង តាមអី?

បឹក៖ ទេ! ប៉ុល ពតហើយនៅតាមផ្ទះ ។

ដានី៖ ជំនាន់ប៉ុល ពត ជំនាន់បាយរួម?

បឹក៖ ទេ! បាយរួមនៅតាមផ្ទះហ្នឹង ។

ដានី៖ នៅតាមផ្ទះ ចឹង?

បឹក៖ គេរួមតែបាយហូបណា ដល់ហូបរួចក៏មកដេក ។

ដានី៖ គេអត់ឲ្យ កូនចៅគេអត់ឲ្យមកនៅខាងកងចល័ត អត់ទៅកងកុមារ ទៅនៅឆ្ងាយៗទេ?

បឹក៖ អត់ទេ! ភូមិយើងអត់ទេ ។

ដានី៖ អត់ទេណ៎?

បឹក៖ ចា៎ស! បើគេទៅរំចេកហើយថានោះ កូនក្មេងអីគេប្រមូលទៅដេកហ្នឹង ហើយកូនខ្ញុំ មីស្រី ដែលនៅសព្វថ្ងៃនេះណា អានោះគេឲ្យធ្វើគ្រូបង្រៀន គេទៅបង្រៀនកូននោះទៅចៅ គេដេកនោះឯង បើនៅរំចេកហើយ ។

ដានី៖ ដល់ពេលយួនមកយ៉ាងម៉េចទៀតទៅ?

បឹក៖ យួនចូលមក! នោះថាបានភ័យចំនាប់ ។

ដានី៖ យួនចូលមកភ័យយ៉ាងម៉េចទៅ?

បឹក៖ យួន!បែកពីបាយរួមហើយ ។

ដានី៖ បែកពីបាយរួម?

បឹក៖ បែកពីបាក់រួម ធ្វើស្រែឯងអញបានស៊ីហើយ យួនវាមកនៅអារហាលនោះត្រពាំងធំណា នៅឯណោះវាប៉ុល ពត ក៏មកវាយអាយួននេះឯង វាយខ្ទាំងក៏នៅនេះនៅហ្នឹងវត្តចាស់ ឃើញតែគ្រង់សេវាដឹក ។ នៅទីនេះវាវាយពេកក៏រាល់ថ្ងៃ ដល់បែកតិចក៏នៅ ទៅនៅកណ្តាលភូមិនេះ នៅហ្នឹងប្រាសាទហ្នឹង សុទ្ធតែខ្មោចយួន ។

ដានី: យួនហ៎? យួនមកនៅកណ្ដាលភូមិបណ្ដោយ?

បឹក: យួនមកនៅកណ្ដាលភូមិបណ្ដោយនេះ ត្រង់នេះថាវាយៗក៏រត់ព្រាតប្រជាជន ខ្លះក៏ត្រូវគ្រាប់ត្រូវគ្រាប់ម្នាក់ មែនហ៎ៗ

ដានី: វាយគ្នាកណ្ដាលភូមិទៅយ៉ាងម៉េច រត់ទៅណាប្រជាជន?

បឹក: រត់បែកបាក់គ្នាខ្ញុំក៏បែកបាក់កូន ខ្ញុំធ្លាក់ទៅសម្បូរ ខ្ញុំក៏ធ្លាក់ទៅកើតទៅចេះៗ

ដានី: ចុះអ៊ីចឹងពេលហ្នឹង ពេលដែលអ្នកភូមិវាយគ្នារត់មកកណ្ដាលភូមិ?

បឹក: រត់បែកនៅភូមិឯងមិនកើតណា ទៅភូមិមួយណា បែកត្រឹមយួននេះឯងៗ

ដានី: ឆ្នាំណាហ្នឹង?

បឹក: មិនដឹងជាឆ្នាំណា បើអត់ស្គាល់ មិនស្គាល់ឆ្នាំស្គាល់ខែៗ

ដានី: បាទ! ដល់ពេលរត់បែកគ្នាចឹង បែកកូនបែកចៅទៅ?

បឹក: បែក! បែកកូនបែកចៅក៏ខ្ញុំនៅនោះទឹកនោះ ក៏កំពង់ទឹក ទឹកស៊ីងណាក៏ហៀរស្រឹព ក៏ហូរលឿនទៀតទឹកកស៊ីងនោះឯងៗ គ្រាន់ចម្លងទម្រាំបានហ្នឹងផុត អត់បាយមួយថ្ងៃវាល់ល្ងាច អត់បាយហូបតាំងពីព្រឹកព្រលឹមហើយថ្ងៃ ថ្ងៃប៉ុននេះបានគេសម្រាកវាយ នៅតាមត្រូវគ្រាប់២នាក់ងាប់ម្នាក់ប្ដីប្រពន្ធ ត្រូវងាប់ប្រពន្ធរបួស ហើយយកប្រពន្ធផ្សេងទៅដាក់ទៀត ប្ដីកាលហ្នឹងងាប់ឯនោះមិនទាន់មករកកប់ទេសម័យនោះ សម័យយួននោះណា ហើយខ្ញុំក៏បាត់កូន ក៏រត់តាមកូន បាត់កូនពីរៗ នៅឯនេះកូនពីរ កូននោះឯងរត់ទៅមុនតាមគេ ភ័យខ្លាំងរត់ទៅឯងរត់ឯណា កំពុងគ្រាប់ចំណាប់ ក្រាបកូនក្រាប នៅកូនពីរបី នៅបីណ៎ រត់ទៅអស់ៗ

ដានី: រត់ទៅអ៊ីទៅនៅឯណា?

បឹក: រត់ទៅ! ទៅនៅព្សរជ្រូក ស្រុកកូលែនយើងនេះឯងៗ

ដានី: នៅកន្លែងព្សរជ្រូកហ៎?

បឹក: ចា៎ស! ដល់ទៅនៅក៏ បានប៉ុន្មានបាន៦ខែ ៦ខែក៏ទៅធ្វើទុក្ខនៅឯនោះទៀត ទៅធ្វើទុក្ខវាយអើយៗ ក៏រត់ចេញវាលទៀតក៏បានវាគៀយកមក យកមកក៏ភ័យអើយៗ

ដានី: ពីណាគៀមក?

បឹក: ប៉ុល ពតៗ

ដានី: ប៉ុល ពតគៀទៅណា?

បឹក: គៀទៅនៅនោះ ទៅឡើងភ្នំនៅឯនោះ ទៅនៅសម្រេចអាដែលចុះមកទៅនៅឯជាំសាលាបានបីឆ្នាំ បួនឆ្នាំៗ

ដានី: ទៅណាឯណា?

បឹក: ជាំសាលា ។

ដានី: នៅជាំសាលា?

បឹក: នៅជាំសាលា នៅបៀតទៅថៃណា បៀតទៅរលាយ ស្រុករលាយនេះឯងប្រមាណបីឆ្នាំ បួនឆ្នាំ បានបែក ជា១០ទៅអស់ខ្ញុំនិយាយពីរត់ អាយប់ក៏រត់ទាំងយប់ ឡូតែគ្រាប់ផ្លោង គ្រឹងៗក៏ចេះ នាំគ្នាឯនោះអើ មិនដឹងទៅខាងណារួច នៅធ្វើម៉េចទស្សាប់រស់នៅក៏ចេះ ប៉ុនបាន អាយុវែងបានជួបជុំ កូនចុះមកនេះ ។

ដានី: នៅជាំសាលាប៉ុន្មាន ៦ឆ្នាំ?

បឹក: នៅបាន៦ឆ្នាំ ដែលទើបឡើងទៅ៣ឆ្នាំ ៤ឆ្នាំបាន បានគេថាចប់ ចប់ហើយបានគេថាបងប្អូន ចង់រកស្រុកភូមិទៅវិញក៏ទៅចោះ គេប្រាប់ចឹង ។

ដានី: គេប្រាប់អីចឹង?

បឹក: ចឹងហ៎ ។

ដានី: កាលនៅជាំសាលាហ្នឹង ទៅកាលហ្នឹងទៅជាមួយប៉ុល ពត?

បឹក: ទៅនៅប៉ុល ពត ។

ដានី: ប៉ុល ពត! ពីណាគេប្រធានកាលហ្នឹង?

បឹក: មិនដឹងនរណាគេទេ មិនសូវស្គាល់ទេ មួយជួតាគុយ តាអីគេនោះ ។

ដានី: ពីណាគេ?

បឹក: តា គុយ!មិនសូវស្គាល់ឈ្មោះ ។

ដានី: ស្គាល់ តា ម៉ុក ទេ?

បឹក: តា គុយ ណាឈ្មោះគាត់!

ដានី: ប៉ុនតា ម៉ុក, ស្គាល់តា ម៉ុកទេ?

បឹក: និយាយមិនស្គាល់!

ដានី: នៅកន្លែងតាម៉ុក?

បឹក: នៅកន្លែងនេះឯង គាត់ថាកន្លែងៗផ្ទះស្នាក់គាត់នេះឯង ប៉ុនគាត់នៅតែស្រុកថៃ ហើយមាន បានឃើញណា ពេលដែលទៅជួបថ្មីនោះគ្រាន់តែដៃជើងទេ ដល់យួនឡើងមកដល់ទេ បានដាច់ ជើង ។

ដានី: ដែលឃើញតាម៉ុក ហើយដែលបាននិយាយជាមួយគាត់ទេអ៊ី?

បឹក: ទេ!មិនដែលទៅហាននិយាយអី គេអ្នកធំ ។

ដានី: តាម៉ុក មនុស្សគាត់ម៉េចដែរ?

បឹកៈ មនុស្សយើងហ្នឹងណាខ្មែរយើងណា ដូចគ្នាណាអ្នកក្រអ្នកក្សត់ដូចតែគ្នាតា ម៉ុក ។ គាត់មានអីពីដើមនោះ ។ ប៉ុណ្ណេះឯង ប៉ុនដល់ពេលគាត់ឡើងមេទេបានគាត់មានចែកកូន ចែកចៅនេះ ។ ដូចយើងសព្វថ្ងៃនេះណា៎ បើយើងមានមុខមានមាត់ធ្វើមេធ្វើបាគេហើយក៏អង្គការចេះតែផ្តល់ទៅអ្នកធំ ចែកកូនចែកចៅចុះដូចតែគ្នា ។

ដានីៈ ដល់ពេលទៅកន្លែងជាមួយប៉ុល ពតយ៉ាងម៉េចដែរ ស្រួល ឬក៏លំបាក?

បឹកៈ ដឹងស្រួលអី! ប៉ុនទៅហើយ ចេះតែនៅទៅណា វាកើតអីរឿងស៊ីរឿងចុកអត់កើតអីទេ ។

ដានីៈ អត់កើតអីទេ? ស្រួលតា?

បឹកៈ គាត់បើកឲ្យទាំងពីសៀង ទាំងពីត្រីខ ទាំងត្រីកម៉ុង តាំងពីស្ករសបីចេងសព្វគ្រប់ណាអើ! គេបើកឲ្យ មិនកំសត់ហូបទេ ។

ដានីៈ ប៉ុនទៅនៅជួបជុំកូនចៅដែរ?

បឹកៈ ជួបជុំទាំងអស់កូន ដល់ចុះមកនេះឯងធ្វើស្រែបានមួយឆ្នាំពីរក៏វាចូលប៉ារ៉ាវាឆ្អឹបទៀត ។

ដានីៈ ពីណាគេចូល?

បឹកៈ ហើយកូនៗខ្ញុំនេះណាពីរ ។ អាពៅមួយ អាបន្ទាប់មួយ អាបង ប៉ារ៉ាចូលមកក៏ទៅខាងប៉ារ៉ា ។ ដល់ប៉ារ៉ាទៅ ខ្មែរក្រហមវាវាយៗងាប់នេះឯងពីរ ប្តីនេះឯងមួយ មីកូន អាប្អូននេះមួយស្លាប់ពីរទៅ ។ អាមួនោះគេនៅខាងខ្មែរក្រហមនេះឯង កាលនេះស្លាប់នឹងប្រាសាទនេះឯងព្រៃស ដាន់មីនហ៊ូ!មីន វាផ្ទុះមីនគេបរទេះដាន់ មីន៦៩ ។ នេះបានថាសព្វថ្ងៃអស់ហើយអាមួយ ងាប់ទៀតក៏នៅតែប្រុសមួយ ស្រី២ប៉ុនណ្ណោះឯង អស់ហើយអត់មានកូន ចៅទេសព្វថៃ បានតែចៅៗទេ ។ គេបានប្រពន្ធនេះទៅ គេនៅនេះបៀត(ស្តាប់ពុំបាន) ។

ដានីៈ ចុះអ៊ុំ កាលពីនៅជាមួយតាម៉ុកនៅជាំសាលាអី កូនចៅកាលហ្នឹងនៅជាប្រជាជនធម្មតា ឬក៏យើងចូលកងទ័ពជាមួយខ្មែរក្រហមដែរ?

បឹកៈ នៅធម្មតានេះណា ចូលអាដែលស្រាប់ណា គឺចូល!

ដានីៈ ចូលធ្វើកងទ័ពខ្មែរក្រហម?

បឹកៈ មិបានចូលធ្វើអីទេ! គ្រាន់តែដឹកជញ្ជូនគ្រាន់ឲ្យណា, បើមិនដឹកជញ្ជូន ខ្លាចគេវាយស្លាប់ ។

ដានីៈ ហ៊ូ! ខាងដឹកជញ្ជូន ។

បឹកៈ នោះឯងក្រុមដឹកជញ្ជូន តាំងពីកូនស្រី កូនអីនោះហ៊ូ ឲ្យដឹកជញ្ជូនគ្រាប់ទៅឲ្យនោះឯង ។

ដានីៈ ចុះកូនអ៊ុំ ពូប្រធានភូមិពូឌឿន គាត់ធ្វើអីដែរ?

បឹកៈ ស្រាប់តែមួយសារនោះឯង ជញ្ជូនគ្រាប់ឲ្យគេដែរ ។

ដានីៈ ជញ្ជូនគ្រាប់ឲ្យគេដែរ?

បឹកៈ ហ្នឹងហើយ! ដាន់ប៉ះមីន ដាច់ជើងដាច់អី ។

ដានីៈ ចុះអ៊ុំកាលហ្នឹងគេមានឲ្យធ្វើអីដែរ?

បឹកៈ ហ៊ឺ! ខ្ញុំមិនដែលឲ្យធ្វើអី! មិនដែលទៅហានគេចុះទេ នៅតែផ្ទះ ។

ដានីៈ នៅតែផ្ទះ! នៅផ្ទះធ្វើអីទៅ?

បឹកៈ ដាំបាយដាំអីហូបទេទៅណា មានធ្វើអីទៅ មានទៅយ៉ាងចុះ ។

ដានីៈ គេអត់មានឲ្យជួយ បិតចំរូងបិតអីទេ?

បឹកៈ តូចៗចឹង! ទីណាក៏ធ្វើផ្ទះបាននៅៗ ទីណាក៏ធ្វើ គ្រាន់តែពង្រួមគល់ឈើក៏ ប្រក់ផ្ទះកៅស៊ូនោះឯង ក៏ដេកតែប៉ុណ្ណោះឯង ។

ដានីៈ ប៉ុន្តែគេអត់មានបិតចំរ៉ូង បិតអីទេ?

បឹកៈ ទេ! គេពុំឲ្យបិតទេ!

ដានីៈ អត់ទេណ៎?

បឹកៈ ទេ! កូនៗក៏បានថ្ងៃណា គេហៅដឹកជញ្ជូន ក៏ទៅឲ្យដឹកជញ្ជូន ។

ដានីៈ នៅជាំសាលារហូតអត់មានត្រលប់ទៅណាទៅណី?

បឹកៈ នៅជាំសាលា! អត់មានទៅណាទេ ។ នៅទីនោះដល់គេបានចប់ ហើយធូរហើយក៏មក ចុះមកសល់ម៉ែចាស់មួយ ម៉ែនៅ គាត់មិនទាន់កើតអីទេនៅសម័យនោះ ក៏សែងម៉ែមកពីណាកូនៗនៅមុននេះ គេទៅយក៥,៦,៧នាក់ទៅ យកមកសែងប៉ុណ្ណោះឯងម៉ែចាស់ គាត់មកនៅបាន១ឆ្នាំ,២ឆ្នាំក៏គាត់ស្លាប់ ។

ដានីៈ គាត់ខូច! គាត់អាយុច្រើនទេ?

បឹកៈ កៅទៅហើយ ជិត១០០ហើយ ។

ដានីៈ ច្រើនហើយណាណ៎?

បឹកៈ ហ្នឹងឯង! បើអាយុគាត់បានថ្ងៃ ខ្លាំងគេគ្រាប់គ្លីងៗហើយគាត់អត់អីទេ ។

ដានីៈ ចុះអ៊ុំកាលដល់ពេលសមាហរណកម្មហើយគេឲ្យត្រលប់មកផ្ទះវិញ?

បឹកៈ ត្រលប់មកផ្ទះវិញ ។

ដានីៈ ចុះយើងកាលហ្នឹង សមារណកម្មហើយបានអ៊ុំមកនៅអន្លង់វែងនេះគេ?

បឹកៈ មិនបានធ្លាក់ទៅទេ! ទៅនោះអន្លងវែង អន្លង់អីហ្នឹងណា ។

ដានីៈ អត់ទៅទេណ៎?

បឹកៈ ទេ! មិនបានធ្លាក់ទៅទេស្រាប់តែដល់អីនេះ ។

ដានីៈ កន្លែងអីគេ?

បឹកៈ ដល់អី មិនដឹងចុះទៅណាទេ ចេះតែចុះ!

ដានីៈ ព្រះប្រឡាយ?

បឹកៈ ព្រះប្រឡាយ អើ!

ដានីៈ អត់នៅព្រាំងប្រាសាទទេ?

បឹកៈ ទេ! ត្រពាំងប្រាសាទក៏មិនបាននៅ អត់នៅទនោះព្រះប្រឡាយបានប៉ុន្មានខែ ក៏ថាយក មកវិញ ។

ដានីៈ ពេលមកវិញ មកដល់ស្រុកភូមិយើងវិញម៉េចដែរ?

បឹកៈ មកដល់ធ្វើស្រែបានមួយឆ្នាំ ក៏គេវាយទៀតរត់ចោលនោះ ក៏គេយកទៅនោះទៀត គេគៀយកទៅព្យួរជ្រូក ។

ដានីៈ ទៅព្យួជ្រូកទៀត?

បឹកៈ ទៅព្យួរជ្រូកបាន៥ឆ្នាំទៀត បានចប់មែនទែន គេឲ្យមកនៅនេះ ។

ដានីៈ ចុះផ្ទះយើងដែលពីមុនមក ដល់ពេលយើងមកវិញយ៉ាងម៉េចទៅ?

បឹកៈ ហ៊ូ! រលីងអស់ ។

ដានីៈ អាលីងវាយ៉ាងម៉េច? គេរុះអស់ ឬក៏ឆេះ?

បឹកៈ គេរុះ! គេដុតឆេះអស់ ។ មកពិបាកកាប់សសរធ្វើ រូងនៅផ្ទះនៅ កើតអីសល់ទេ!

ដានីៈ មកដល់ដឹបូងបានតិចទៅព្យួរជ្រូក មួយសារទៀត?

បឹកៈ ចា៎ស!

ដានីៈ ទៅបាន៥ឆ្នាំ?

បឹកៈ ធ្វើស្រែបានតែមួយឆ្នាំនោះឯង ។

ដានីៈ ចុះផ្ទះហ្នឹង ដល់ពេលដល់ពេលទៅ?

បឹកៈ ស្រូវដាក់ជង្រុកធ្វើវាន ជង្រុកហ្នឹងក៏ដាក់ស្រូវក៏ពេញធ្វើស្រែណាអើ! ធ្វើហ្នឹងគោវាសល់គោបាន មួយនឹម ក្របីគោមួយនឹម ក៏បានធ្វើស្រែ ។

ដានីៈ ធ្វើស្រែធ្វើផ្ទះធ្វើអីទៅ?

បឹកៈ ធ្វើស្រែក៏បានស្រូវនោះ អ៊ំធំគ្រាន់ហើយបើជង្រុកសព្វថ្ងៃនោះសំនំហើយណាស្រូវ ក៏គេបាញ់គេវាយគ្គីង១ក៏ស្លាប់កូនក៏រត់ចោលកូន មានបានទៅរកកូនកប់ណាត្រលប់មកវិញ ទៅរកកូន១រកកប់ក្រោយ ។

ដានីៈ ស្លាប់កូនមួយពេលសង្គ្រាមហ្នឹង?

បឹកៈ ស្លាប់ពីរ ។

ដានីៈ ស្លាប់ដោយសារយ៉ាងម៉េច ឈឺ ឬយ៉ាង?

បឺកៈ ស្លាប់កូនប្រសារមួយ ត្រូវគ្រាប់គេ បើគេបាញ់នោះ ។

ដានីៈ ត្រូវគ្រាប់ខាងណា?

បឺកៈ នៅឯនោះឯង ខាងប៉ុល ពត ។

ដានីៈ ខាងប៉ុល ពត បាញ់?

បឺកៈ ហ្នឹងហើយ ។

ដានីៈ ប៉ុល ពត បាញ់ជាមួយនរណា?

បឺកៈ ប៉ារ៉ា!

ដានីៈ បាញ់ជាមួយប៉ារ៉ា?

បឺកៈ ឯនោះឯង ។

ដានីៈ ស្លាប់នៅឯណា?

បឺកៈ ប៉ារ៉ាចូលភូមិ! អាប្រាសាទឯកើត ។

ដានីៈ ស្លាប់ឯប្រាសាទកើត ស្លាប់ទៅរត់ទៅអត់បានកប់ទេ?

បឺកៈ អត់បានកប់ទេ ក៏មករកកប់ក្រោយ ។

ដានីៈ ប្រាំឆ្នាំក្រោយបានមករកកប់?

បឺកៈ ទេ! ទៅបានមួយយប់ពីរយប់ក៏វាមក យកតែម៉ែទៅទុកណាដែលវាបែកបាក់គ្នានោះ ។

ដានីៈ បានមករកកប់ខាងក្រោយ?

បឺកៈ បានមករកកប់!

ដានីៈ បានរកឃើញអត់?

បឺកៈ ពីរ! ស្លាប់កូនប្រសារមួយ អានោះកូនគាត់មួយ ។

ដានីៈ ពីរនាក់! បានមករកប់ឃើញ បានកប់ទេ?

បឺកៈ ខ្ញុំវាង! ឃើញទាំងពីរនេះឯង, បានកប់បានដុតទាំងអស់ ។ គេដុតយកតែធាតុទៅ យកទៅធ្វើបុណ្យនៅព្សរជ្រូក ។

ដានីៈ យកទៅធ្វើបុណ្យខាងនៅព្សរជ្រូកនោះទៅ?

បឺកៈ មនាលោកមានអីនៅ ។ គេមានរត់មានអីគេខាងនោះ រត់តែយើងខាងនេះ ។

ដានីៈ ដល់ពេលបាន៥ឆ្នាំបានត្រលប់មកនៅឯនេះវិញ?

បឺកៈ ហ្នឹងហើយ!

ដានីៈ ត្រលប់មក មកនៅផ្ទះកន្លែងដដែរវិញហ៉?

បឹកៈ នៅផ្ទះនេះឯង ។

ដានីៈ កន្លែងដដែរ ឬក៏អត់នេះ?

បឹកៈ ធ្វើកន្លែងដដែរនេះ, ពីដើមធ្វើទៅ មុនខាងនោះអាពោងគោ នេះទីនេះ អាររន្ទោល ។

ដានីៈ ផ្ទះនេះទើបតែធ្វើទេ?

បឹកៈ ផ្ទះនេះទើបតែធ្វើទេ ធ្វើបាន៥,៦ហើយនេះ ។

ដានីៈ ទើបតែធ្វើបាន៥,៦ឆ្នាំហ៎ហ៎?

បឹកៈ ចាស!

ដានីៈ កាលធ្វើផ្ទះហ្នឹង?

បឹកៈ បានចិញ្ចឹមជ្រូក បានអី បានដូរគោ បានកើតកូនកើតអី បានគោលក់ បានធ្វើផ្ទះ ។

ដានីៈ បាទ! ប៉ុនពេលធ្វើផ្ទះហ្នឹង អប្សរាគេអត់ទាន់មកទេ?

បឹកៈ អត់ទាន់មកទេ! ផ្ទះខ្ញុំធ្វើយូរណាស់ហើយធ្វើនោះ ។

ដានីៈ ដល់ពេលធ្វើហើយបានអប្សរាគេមក?

បឹកៈ ហ្នឹងហើយ អប្សរាគេមកក្រោយ ។

ដានីៈ បើអប្សរាគេមកមុនគេអត់ឲ្យធ្វើទេ?

បឹកៈ មិនឲ្យធ្វើទេ! ប៉ុនមិនធ្វើក៏នៅតែនិយាយខ្វះដេញដោលគ្នា ចុះបើនេះធ្វើយូរណាស់ហើយផ្ទះ ។

ដានីៈ ចុះឥឡូវយ៉ាងម៉េចទៀត យ៉ាងម៉េចទៀត ដល់ពេលក្រោយ?

បឹកៈ មិនដឹងទេសព្វថ្ងៃ មិនដែលគេសួរខ្ញុំទេ! មិនទាន់ព្មថាអី ។

ដានីៈ ហ៊ឹម! មិនដែលព្មថាអីទេ?

បឹកៈ ទេ! អប្សរាពេលមកមុនដឹបូងតានោះ តាអី! តា ណមៗ មកមុន ។

ដានីៈ មកថាម៉េច?

បឹកៈ មកមុនខ្ញុំលើកហើយផ្ទះ ។ មកមុនថាអីទេ យាយស្រែផ្ទះជុំវិញ យាយលក់ឥឡូវទេ? ទេត្រូវថ្លៃគ្នាលក់ទៅ លក់ប៉ុណ្ណាយាយ? យកទៅខ្ញុំយកតែ១ម៉ឺនដុល្លាទេ ។

ដានីៈ យកតែ១ម៉ឺន?

បឹកៈ ១ម៉ឺនដុល្លា ក៏សើចផង តាកុក តាអីណានៅក៏ដើទៅប៉ុណ្ណោះ ប៉ុណ្ណោះឯងតែម្តង ដែលនរណាគេសួរខ្ញុំទេ ។

ដានីៈ ចុះអ៊ុំ ដោយថាអ៊ុំធ្លាប់ឆ្លងកាត់ពីដើមតាំងពីសម័យអ៊ុំនៅតូច តាំងពីសម័យសង្គ្រាម រហូតដល់សម័យសង្គ្រាម ម៉េចដែលជីវិតខុសគ្នាដែរ ឬទេ?

បឹកៈ ជីវិតខុសគ្នានេះណា ពីដើមមិញវាផ្សេង សព្វថ្ងៃគេដូចថាគេរកស៊ី គ្រាន់ទៅគេលក់គេដូរគេស៊ីទៅ គេរកដូរធារ គេរកលុយប្រាក់កាក់ណា គេអ្នកបេះរកដូចអស់ខ្ញុំនោះ ឈប់រកអីបានហើយ ចាយដោយសារកូនចៅ ។

ដានីៈ ចាយដោយសារកូនចៅ?

បឹកៈ នោះឯង!

ដានីៈ ប៉ុន្តែសម័យឥឡូវសម្បូរសប្បាយជាងពីមុន ឬក៏ពីមុនសប្បាយជាង?

បឹកៈ គេសម្បូរសប្បាយជាងយើងពីមុន យើងពីមុនមានអ្នកណាទិញលក់នោះទៅ បានស្រែបានស្រូវក៏ នៅពេញផ្ទះ ចិញ្ចឹមជ្រូកមាន់នោះ?

ដានីៈ ចុះកាលពីសម័យសង្គ្រាមស្រួល ឬក៏លំបាក សម័យសង្គ្រាម?

បឹកៈ ហ៊ូ!សង្គ្រាមលំបាកកម្មលើសអីទៀតណ៎ាកូន ។

ដានីៈ ចុះដៃអ៊ីដៃ កើតអីគេ?

បឹកៈ បាក់ទេ១! ធ្លាក់ពីលើដើមឈើក៏បាក់ អត់កើតអីទេ ។ ជៀសវាងផុត មិនកើតអីទេ ដែលសង្គ្រាម ។

ដានីៈ ចុះអ៊ុំ ខ្ញុំដូចជាអត់មានអីចង់សួនាំអ៊ុំអីទៀត ចុះអ៊ុំមានសំណូមពរអីចង់ អើ!ទាក់ទងពីស៊ីក៏ដោយដែលអ៊ុំចង់មានសំណូមពរអីដែរអត់ ចង់បន្ថែម ឬក៏ចង់មានសំណូមពរ ។

បឹកៈ អើយ! គ្មានអីផង ។ ចាស់ហើយមិនដឹងណាទេ មិនដឹងយាយម៉េចអីម៉េចទេ ។

ដានីៈ ចុះអ៊ុំប្រាសាទយើង កាលពីមុនហើយឥឡូវខុសគ្នាម៉េចដែរ?

បឹកៈ ខុសគ្នាណា ពីដើមមុនដំបូងមិនដែរត្រួសជីចម្ការ ឥឡូវគេត្រួសចម្ការជ្រះស្រលះស្អាត របស់គេ ។

ដានីៈ កាលពីមុនគេពុំដែលត្រួសទេណ៎ា តាំងពីអ៊ុំនៅក្មេង១មិនដែរត្រួសទេណ៎ា?

បឹកៈ មិនដែរត្រួសទេ ។

ដានីៈ មិនដែលត្រួសទេ?

បឹកៈ សូម្បីតែស្រះ ក៏ពុំដែលត្រួសដែលឆ្ការ ស្រះទឹកហ្នឹង ។

ដានីៈ ស្រះទឹកហ៎េ?

បឹកៈ នៅស្តុកស្រុកពីដើម ប៉ុនទឹកត្រជាក់ណាស់ស្រុកពីដើម ហើយសព្វថ្ងៃអត់ទេទឹក ដូចផ្លូតទឹកត្រពាំង ។

ដានីៈ កាលពីមុនស្តុកច្រើនហ៎េ?

បឹកៈ ស្តុកច្រើនត្រជាក់ ទឹកខ្មៅ ផ្លូត, មានស្មីមាននៅសព្វនោះ ។

ដានី: ស្អីនៅ?

ប៊ីក: ពស់ ក្រពើ អីនៅ ។

ដានី: ឥឡូវមានអត់ពស់ក្រពើ?

ប៊ីក: មានខ្លះ ដូចអត់មានទឹកហើយ ។

ដានី: ស្រះនៅក្នុងប្រាសាទហ្នឹង?

ប៊ីក: នោះហើយ ។

ដានី: កាលមុនមានពស់ មានក្រពើអីនៅ?

ប៊ីក: ហើយសព្វថ្ងៃក៏ពុំអត់ដែរ ។

ដានី: សព្វថ្ងៃក៏នៅដែរ?

ប៊ីក: ឃើញតាំងពីដែលគេបាវស្រះអី ។

ដានី: គេបាវស្រះ?

ប៊ីក: បាវស្រះ!

ដានី: គេបាវ យកអី?

ប៊ីក: គេបាវ យកសម្រាមចេញ ។

ដានី: យកអី?

ប៊ីក: បាវ យកសម្រាមចេញ!

ដានី: យកសម្រាមចេញមានសត្វ ជួបក្រពើ ។

ប៊ីក: ជួបទេ! ប៉ុនវាឃើញ គេឲ្យឃើញហ្នឹងណា ក្រពើម្ចាស់ទឹកម្ចាស់ដីគេណាស់ ឃើញតា ។

ដានី: តែអ៊ុំ មានប្រសាសន៍ម៉េចថាម៉េច ដល់ពេលកាប់ឆ្ការព្រៃអស់ទៅ ធ្វើឲ្យប្រាសាទហ្នឹងរបេះ?

ប៊ីក: អើ! ចុះ ថាចុះបើភ្លៀងមកមិនឃើញរបេះៗ ពីដើមមិនដែលរបេះទេរបស់ទាំងអស់នោះ ។

ដានី: ហ៊ឹមចឹងណ៎!

ប៊ីក: ឡើងប្រតែងតាមឈើនោះ ឡើងទៅមើលប្រាសាទនោះ ទៅអាដែលបាក់មកជណ្ដើរអាក្រោមណា! វាបាក់នោះឯង ឡើងប្រតែងតាមនោះទៅអាជណ្ដើរនោះចេះឡើងទៅ ។ ប្រតែងតាមឈើទៅ ។

ដានី: ចុះបើតាមចិត្តអ៊ុំវិញ អ៊ុំគិតថាយើងទុកព្រៃស្តុកវាល្អជាងយើងឆ្ការ ឬក៏ម៉េច?

ប៊ីក: ព្រៃស្តុកនោះវាល្អដែលណ៎ ប៉ុនសព្វថ្ងៃកាប់ឈើអស់ហើយ គេកាប់ពុំដឹងថាអាធំអីទេ គេកាប់តែអាតូចៗ អាធំវាចាក់ឬសនេះទៅ មិនដែលបាន គេកាប់អស់ហើយ ។

ដានី: ចុះអ៊ុំរាល់ថ្ងៃ អ៊ុំដូច ថាអ៊ុំមានការណ៍ អាក់អន់ចិត្តជាមួយអាជ្ញាធរអប្សរាទេ?

បឹកៈ ទេ! អន់អីទេ គេកូនចៅគេធ្វើយ៉ាងបានស្អាតល្អបេះតែធ្វើទៅ គេកសាងរបស់គេហើយស្អាត ។

ដានីៈ ចុះបើទាក់ទងអង្គការអភិវឌ្ឍន៍ដីជុំវិញហើយហ្នឹង ដូចថាមានការប៉ះពាល់អីជាមួយអ៊ុំ ជាមួយអ្នកស្រុកអ្នកភូមិដែរទេ?

បឹកៈ អ៊ូ! ប៉ះពាល់ក៏គេនិយាយតាមនោះទៅណា សុំគេតែប៉ុណ្ណឹង ។

ដានីៈ បាទ! អ៊ុំ ខ្ញុំជាអស់មានអីដែលត្រូវសួរអ៊ុំទៀតហើយ ។

បឹកៈ អើ! មិនកើតអីទេកូន ។

ដានីៈ បាទ! ខ្ញុំអគុណច្រើន ។

**«ចប់»**